BBI0009

មជ្ឈមណ្ឌលឯកសារកម្ពុជា

**ជិន គាក់ ហៅ ម៉ឺន, ភេទប្រុស** K09005 **(បាត់ខ្លួន)**

**កូនទីៈ សមាជិកសហករណ៍ដាំស្លែ**

**សម្ភាសជាមួយ ជួន គុំ, អាយុ ៧៣ឆ្នាំ, ត្រូវជាប្រពន្ធ**

**និង គាក់ ឃួន, អាយុ៤០ឆ្នាំ ត្រូវជាកូនស្រី**

**ភូមិស្នួស្តី ឃុំតាលាស់ ស្រុកមោង ខេត្តបាត់ដំបង**

**ថ្ងៃទី១០ កក្កដា ២០០៦**

*សំភាសដោយៈ វ៉ា នៃវ៉ាន់*

**នៃវ៉ាន់ៈ** អត់ទោសលោកយាយឈ្មោះអីដែរ?

**គុំៈ** ឈ្មោះជួន គុំ ។

**នៃវ៉ាន់ៈ** សព្វថ្ងៃលោកយាយអាយុប៉ុន្មានហើយ?

**គុំៈ** ៧២, ៧៣ ។

**នៃវ៉ាន់ៈ** លោកយាយឆ្នាំខ្មែរលោកយាយកើតឆ្នាំអីទៅ?

**គុំៈ** លោកយាយឆ្នាំខ្មែរលោកយាយកើតឆ្នាំអីទៅ?

**នៃវ៉ាន់ៈ** ឆ្នាំកុរ, លោកយាយមានស្រុកកំណើតកើតនៅណាដែរ?

**គុំៈ** កើតនៅហ្នឹងឯង ។

**នៃវ៉ាន់ៈ** ភូមិអីគេ?

**គុំៈ** ភូមិស្តី, ឃុំតាលាស់ ស្រុកមោងឫស្សី ។

**នៃវ៉ាន់ៈ** ចុះសព្វថ្ងៃហ្នឹងលោកយាយរស់នៅក្នុងភូមិឃុំដដែល?

**គុំៈ** អត់ប្តូរផង នៅដដែល ។

**នៃវ៉ាន់ៈ** ឪពុកម្តាយលោកយាយឈ្មោះអីដែរ?

**គុំៈ** ឈ្មោះយាយស៊ូ តានិល ។

**នៃវ៉ាន់ៈ** តានិល យាយស៊ូ, សព្វថ្ងៃគាត់ខូចអស់ហើយ, ខូចតាំងពីជំនាន់ណាយាយ?

**តុំ:** ជំនាន់ណា ពុកខ្ញុំខូចតាំងពីសង្គមម្ជេះ ម្ដាយខ្ញុំខូចឆ្នាំ១៩៨៣ ។

**នៃវ៉ាន់:** ចុះលោកយាយមានបងប្អូនប៉ុន្មាននាក់?

**តុំ:** បងប្អូន៦នាក់ ។

**នៃវ៉ាន់:** ប្រុសប៉ុន្មានស្រីប៉ុន្មានទៅលោកយាយ?

**តុំ:** ប្រុសបី ស្រីពីរ ។

**នៃវ៉ាន់:** ស្រីបីតាំងយាយ, ចុះលោកយាយជិន គាត់ហ្នឹងត្រូវម៉េចជាមួយលោកយាយដែរ?

**តុំ:** ហ្នឹងហើយ គ្រួសារ ។

**នៃវ៉ាន់:** ជិន គាត់ហ្នឹងលោកយាយដឹងថាគាត់អ្នកស្រុកណាដែរ? គាត់កើតជានៅណាដែរ?

**តុំ:** ស្រុកកំណើតគាត់ហ្នឹងឯង ។

**នៃវ៉ាន់:** នៅក្នុងភូមិស្ដីហ្នឹង?

**តុំ:** ភូមិស្ដីហ្នឹង ។

**នៃវ៉ាន់:** លោកយាយដឹងថាជិន គាត់ហ្នឹងគាត់កើតឆ្នាំណាដែរអត់?

**តុំ:** អត់ដឹងទេ ។

**នៃវ៉ាន់:** ឆ្នាំខ្មែរយើងលោកយាយដឹងទេ?

**តុំ:** ភ្លេចភ្លាំងអស់ហើយខ្ញុំ ។

**នៃវ៉ាន់:** បងយាយអីក៏ប្អូនលោកយាយគាត់ហ្នឹង?

**តុំ:** ប្អូន ។

**នៃវ៉ាន់:** ប្អូនប៉ុន្មានឆ្នាំ?

**តុំ:** ប្អូនប៉ុន្មានឆ្នាំទេ យូរដែរអត់ចាំអត់អីផង ។

**នៃវ៉ាន់:** ចុះឪពុកម្ដាយតាគាត់ហ្នឹងគាត់ឈ្មោះអីទៅ ?

**តុំ:** ឈ្មោះជិន, យាយហាំ ។

**នៃវ៉ាន់:** ឪពុកឈ្មោះ?

**តុំ:** ជិន, ម្ដាយឈ្មោះហាំ ។

**នៃវ៉ាន់:** ខូចអស់ហើយ?

**តុំ:** អស់ហើយ ។

**ណៃវ៉ាន់:** ខួបតាំងពីជំនាន់ណាទៅយាយ?

**តុំ:** តាំងពីសង្គមម្ទេះ ។

**ណៃវ៉ាន់:** យាយចុះ, គាត់ហ្នឹងគាត់មានបងប្អូនប៉ុន្មាននាក់?

**តុំ:** បងប្អូនមើលប្អូននាក់, គេទៅណាអស់ហើយ ។

**ណៃវ៉ាន់:** ប្អូននាក់ហ្នឹងគិតតាំងគាត់?

**តុំ:** ចា៎ស! ទាំងគាត់ ។

**ណៃវ៉ាន់:** ប្រុសប៉ុន្មានស្រីប៉ុន្មានដែរ?

**តុំ:** ប្រុសពីរ ស្រីពីរ ។

**ណៃវ៉ាន់:** កូនទីមួយណាគេ?

**តុំ:** គាត់ហ្នឹងហ្មង ។

**ណៃវ៉ាន់:** ទីពីរឈ្មោះអីយាយ?

**តុំ:** ឈ្មោះយ៉េត ។

**ណៃវ៉ាន់:** ជិន យ៉េត, ស្រីអីប្រុស?

**តុំ:** ប្រុស ។

**ណៃវ៉ាន់:** សព្វថ្ងៃគាត់នៅរស់អីស្លាប់?

**តុំ:** នៅ ។

**ណៃវ៉ាន់:** នៅណាដែរ?

**តុំ:** នៅឯភ្នំក្រពើណោះ ។

**ណៃវ៉ាន់:** ចុះទីបី?

**តុំ:** ទីបីឈ្មោះរើន?

**ណៃវ៉ាន់:** ស្រីអីប្រុស?

**តុំ:** ស្រី ។

**ណៃវ៉ាន់:** សព្វថ្ងៃគាត់រស់អីក៏ស្លាប់ហើយ?

**តុំ:** នៅ នៅពីរនាក់បងប្អូនគាត់នៅនឹងបងប្អូនគាត់ហ្នឹងឯង ។

**ណៃវ៉ាន់:** នៅភ្នំក្រពើហ្នឹង?

**ឃួនៈ** ភ្នំក្រពើ ។

**នៃវ៉ាន់ៈ** ចុះទីបួន?

**ឃួនៈ** ទីបួនគាត់ស្លាប់តាំងពីសម័យតស៊ូជាមួយនឹងគាត់ហ្នឹង ឈ្មោះបុិ ។

**នៃវ៉ាន់ៈ** បុិហ្នឹងស្រីអីប្រុស?

**ឃួនៈ** ស្រី ។

**នៃវ៉ាន់ៈ** ស្លាប់ហើយតាំងពីជំនាន់ខ្មែរក្រហម?

**ឃួនៈ** ស្លាប់គាត់ដឹងដែរតើ តាំងពី៧០គត់ ជំនាន់៧០ណោះ ។

**នៃវ៉ាន់ៈ** ថីបានស្លាប់?

**ឃួនៈ** គាត់ស្លាប់ដោយសារកប៉ាល់បាញ់អីមិនដឹង ខ្ញុំដូចស្រពិចស្រពិល ។

**នៃវ៉ាន់ៈ** គាត់ស្លាប់ដោយសារទម្លាក់គ្រាប់កប៉ាល់ហោះហ្នឹងមែន?

**គុំៈ** បែបម៉ាជំនាន់កប៉ាល់ហោះហ្នឹងឯងស្លាប់ហ្នឹងនោះ ។

**នៃវ៉ាន់ៈ** ចុះគាត់គាក់ហ្នឹងកាលពីដើមឡើងគាត់នៅជុំគ្នានៅក្នុងភូមិនេះទាំងអស់ទេបងប្អូនគាត់?

**គុំៈ** នៅហ្នឹងទាំងអស់ ។

**នៃវ៉ាន់ៈ** ចុះលោកយាយតាំងពីក្មេងតាំងពីអីម៉ោគាត់មានបានទៅរៀនទៅអីអត់?

**គុំៈ** គាត់នៅវត្តដែរ កាលហ្នឹងមិនបានរៀន ។

**ឃួនៈ** ខ្ញុំនៅតូចៗឮគាត់និយាយ គាត់ទៅនៅវត្ត តែមិនដឹងបានបួសអីមិនបាន ។

**នៃវ៉ាន់ៈ** លោកយាយដឹងថាគាត់រៀនប្រហែលជាប៉ុន្មានឆ្នាំដែរ?

**គុំៈ** អត់ដឹងប៉ុន្មានឆ្នាំផង ។

**នៃវ៉ាន់ៈ** នៅវត្តណាយាយ?

**គុំៈ** វត្តស្ដីយើងនេះ ។

**នៃវ៉ាន់ៈ** តែកាលហ្នឹងគាត់ចេះសរសេរអីបានធម្មតាដែរអត់?

**ឃួនៈ** ចេះតើ កាលគាត់ធ្វើភូមិហ្នឹងគាត់ចេះសរសេរចេះអីតើ ។

**នៃវ៉ាន់ៈ** ចុះបន្ទាប់ពីគាត់ឈប់នៅវត្តហ្នឹងគាត់ធ្វើអីទៀតទៅ?

**គុំៈ** អត់មានធ្វើអីផង ធ្វើស្រែ ។

**នៃវ៉ាន់ៈ** បន្ទាប់ពីឈប់នៅវត្តហើយ គាត់ម៉ោនៅជាមួយឪពុកម្ដាយធ្វើស្រែធម្មតា?

**គុំ:** មានឪពុកម្ដាយទេ មានតែឪពុកគាត់ឆាប់តាំងពី នៅជាមួយយាយ និងម្ដាយមីង ។

**នៃវ៉ាន់:** អញ្ចឹងពេលគាត់ចេញពីវត្តម៉ោគាត់រៀបការជាមួយលោកយាយអីក៏ម៉េច?

**គុំ:** ម៉ោនឹងខ្ញុំហ្នឹងឯង ក្មេចអស់ហើយ យូរហើយ ។

**នៃវ៉ាន់:** ចុះលោកយាយដូចថា លោកយាយរៀបការជាមួយគាត់ហ្នឹងកាលហ្នឹងមុនរដ្ឋប្រហារទម្លាក់សម្ដេចអីក៏ក្រោយរដ្ឋប្រហារ?

**គុំ:** មុន ។

**ឃួន:** រដ្ឋប្រហារមុនចូលព្រៃទៀតម៉ែឯង បើខ្ញុំកើតក្រោយ ៦៣នេះហើយ ។

**នៃវ៉ាន់:** មុនរដ្ឋប្រហារប្រហែលប៉ុន្មានឆ្នាំដែរ?

**គុំ:** មិនដឹងប៉ុន្មានទេ មិនចាំ ។

**ឃួន:** រឿងគាត់និយាយប្រាប់ខ្ញុំៗចាំ ។

**នៃវ៉ាន់:** កាលលោកយាយការនៅក្នុងស្រុកភូមិហ្នឹងទេ?

**គុំ:** ចា៎ស!

**នៃវ៉ាន់:** ពេលលោកយាយរៀបការជាមួយគាត់ហើយលោកយាយប្រកបមុខរបររធ្វើអីទៅ?

**គុំ:** អត់មានធ្វើអីណា៎ ធ្វើស្រែធ្វើអីហ្នឹង គ្មានរកស៊ីទេ អត់មានចំការទេ ធ្វើស្រែ ។

**នៃវ៉ាន់:** ចុះលោកយាយការហើយរយៈពេលប៉ុន្មានបានមានកូន?

**គុំ:** បានម៉ាឆ្នាំ ។

**នៃវ៉ាន់:** កូនស្រីអីប្រុស?

**គុំ:** កូនសុទ្ធតែស្រី ។

**នៃវ៉ាន់:** ចុះលោកយាយដូចថាដិន តាក់ហ្នឹងគាត់ធ្លាប់ចូលបម្រើបដិវត្តខ្មែរក្រហមដែរអត់?

**គុំ:** ចូលតើ ចូលព្រៃ ។

**នៃវ៉ាន់:** គាត់រត់ចូលព្រៃនឹងគេដែរ?

**គុំ:** ចា៎ស!

**នៃវ៉ាន់:** ឆ្នាំណាដែលគាត់រត់ចូលព្រៃហ្នឹង?

**គុំ:** មិនដឹងឆ្នាំអី បើមិនចាំផង ឆ្នាំ៧០គត់ហ្នឹងឯង ។

**នៃវ៉ាន់:** ៧០គត់ហេ៎, រត់ទៅតស៊ូហេ៎?

**តុំ:** ចា៎ស! រត់ទៅតស៊ូ ។

**នៃវ៉ាន់:** ម៉េចបានគាត់រត់ទៅចូលព្រៃអញ្ចឹងលោកយាយ?

**តុំ:** អត់ដឹងផង គេរត់ទៅ ។

**នៃវ៉ាន់:** គាត់អត់ប្រាប់លោកយាយទេ?

**តុំ:** អត់, ភ្លេចអស់ហើយយូរហើយ ។

**ឃួន:** ដំណើរពេលកាលហ្នឹងគាត់ចាំដែរ តែដល់សព្វថ្ងៃគាត់ភ្លេចបាត់អស់ហើយ ។

**នៃវ៉ាន់:** ពេលគាត់រត់ហ្នឹងកូនស្រីច្បងហ្នឹងអាយុប៉ុន្មានហើយ?

**តុំ:** អាយុប៉ុន្មាន១០ឆ្នាំកាលហ្នឹងហ៎ ។

**ឃួន:** ១០ឯណា ៥ឆ្នាំហ្នឹងឯង៤-៥ហ្នឹងឯង ។

**នៃវ៉ាន់:** ពេលគាត់រត់ទៅចូលព្រៃហ្នឹង ដូចថា ដោយសារគេបង្ខំឲ្យចូលអីក៏គាត់ស្ម័គ្រចិត្តចូល?

**តុំ:** មិនដឹងដែរបើគេទៅ ទៅទាំងភូមិទាំងអស់ហើយ ។

**ឃួន:** ទៅទាំងភូមិនេះបណ្តោយ ។

**នៃវ៉ាន់:** ដូចថាមានគេម៉ោឃោសនាឲ្យទៅ គេបង្ខំឲ្យទៅ ឬក៏គាត់សុខៗទៅហ្នង?

**តុំ:** កាលហ្នឹងគេកៀរទៅទេ ។

**ឃួន:** គេកៀរម៉ាកំណាត់ភូមិនេះទៅទាំងអស់ គ្មានណាសល់មួយទេ ។

**នៃវ៉ាន់:** គេចុះកៀរយកទៅធ្វើ?

**តុំ:** ហ្នឹងហើយ អ្នកភូមិហ្នឹងទាំងអស់យកទៅ ។

**នៃវ៉ាន់:** យកទាំងស្រីទាំងប្រុស?

**តុំ:** យកទាំងអស់ ទាំងស្រីទាំងប្រុស ។

**នៃវ៉ាន់:** ទាំងយាយទាំងអីចូលព្រៃទាំងអស់?

**តុំ:** ចា៎ស! ភូមិនេះយកទាំងអស់ គ្មានណានៅបានមួយទេ ។

**នៃវ៉ាន់:** គេយកទៅ នៅណាទៅ?

**តុំ:** នៅឆ្ងាយណាស់ ភូមិត្របែកណោះ ។

**នៃវ៉ាន់:** ត្របែកនៅណាទៅ?

**តុំ:** ត្របែកក្រោមណោះ ព្រៃនាមណា៎ ។

**ឆៃវ៉ាន់ៈ** អាណឹងនៅក្នុងស្រុកណាអីដែរ?

**តុំៈ** ព្រៃនាម ។

**ឆៃវ៉ាន់ៈ** គេហៅព្រៃនាមហ្នឹងហ្នង?

**តុំៈ** ចា៎ស! គេហៅព្រៃនាមអញ្ចឹងហ្នឹង មានភូមិគេដែរ អាកន្ទែងតស៊ូហ្នឹងវាបែកក្រហែង ។

**ឆៃវ៉ាន់ៈ** ពេលគេគៀរអ្នកស្រុកទៅដល់ព្រៃនមាហ្នឹងគេឲ្យយាយធ្វើអីទៅ?

**តុំៈ** ធ្វើអីផង ។

**ឃួនៈ** គាត់ដើរធ្វើការជាមួយគេដែរ ប៉ុន្មមិនដឹងដើរធ្វើអី ។

**ឆៃវ៉ាន់ៈ** គាត់ធ្វើការជំនាន់ហ្នឹងដែរ?

**តុំៈ** ចា៎ស!

**ឆៃវ៉ាន់ៈ** លោកយាយឃើញគាត់ធ្វើម៉េចខ្លះ ការងារគាត់?

**តុំៈ** មិនដឹងធ្វើម៉េចខ្លះទេ ដើរបាត់ៗទៅមិនដឹងគេធ្វើអី ។

**ឃួនៈ** ដើរពីផ្ទះបាត់ៗហើយ មិនដឹង ។

**ឆៃវ៉ាន់ៈ** ពេលគេគៀរទៅដល់ហ្នឹងគាត់ដូចថា ធ្វើមេក្រុមគេ ដើរឃោសនាគេអីក៏ម៉េច?

**តុំៈ** អត់ដឹង ដឹងតែដើរបាត់ៗ មិនដឹងជាធ្វើអីៗអត់ដឹង ឃើញដើរបាត់ៗទៅ គេមិនប្រាប់ថាធ្វើ នេះធ្វើនោះផង ។

**ឆៃវ៉ាន់ៈ** គាត់អត់មាននិយាយថាធ្វើអីទេ លោកយាយអត់ដែលសួរគាត់ទេ?

**តុំៈ** អត់បានសួរថាធ្វើអីៗផង ខ្ញុំនៅផ្ទះ គេដើរទៅមិនដឹងគេធ្វើអីៗ អត់ដឹង ។

**ឆៃវ៉ាន់ៈ** កាលហ្នឹងគាត់ដើរទៅធ្វើការទៅដល់ណាទៅ?

**តុំៈ** នៅព្រៃ នៅនឹងព្រៃហ្នឹងគ្មានដែលទៅណាម៉ោណាទេ ។

**ឆៃវ៉ាន់ៈ** ចុះគាត់មានកាំភ្លើងមានអីនៅជាប់ខ្លួនដែរអត់?

**តុំៈ** មាន កាលជំនាន់តស៊ូហ្នឹង ។

**ឆៃវ៉ាន់ៈ** កាំភ្លើងខ្លីអីកាំភ្លើងវែង?

**តុំៈ** កាំភ្លើងវែង ។

**ឆៃវ៉ាន់ៈ** តែលោកយាយអត់ដឹងថាគាត់ធ្វើអីទេ?

**តុំៈ** អត់ដឹង បើអត់ប្រាប់ ។

**ឆៃវ៉ាន់ៈ** ដល់ពេលខ្មែរក្រហមឈ្នះ៧៥ទៅ គាត់ធ្វើអីទៅ?

**ឃួនៈ** ធ្វើមេឃុំហ្នឹងឯង ធ្វើគណៈសហករណ៍ហ្នឹងឯង ពេល៧៥ហ្នឹង ។

**ឆៃវ៉ាន់ៈ** ពេលហ្នឹងគាត់ធ្វើគណៈសហករណ៍?

**តុំៈ** ពេល៧៥ហ្នឹងគាត់ចេញធ្វើគណៈសហករណ៍ ។

**ឆៃវ៉ាន់ៈ** ចេញពីណាម៉ោ?

**តុំៈ** ចេញពីព្រៃម៉ោ ។

**ឆៃវ៉ាន់ៈ** ចេញពីព្រៃម៉ោនៅណាវិញ?

**តុំៈ** នៅខាងបាត់ដំបងណោះ ។

**ឆៃវ៉ាន់ៈ** នៅស្រុកបាត់ដំបងណោះ?

**តុំៈ** នៅដាំស្ពៃហ្នឹង ។

**ឆៃវ៉ាន់ៈ** នៅក្នុងភូមិអីគេ?

**តុំៈ** ភូមិដាំស្ពៃ ។

**ឆៃវ៉ាន់ៈ** ពេលឆ្នាំ៧៥ហ្នឹងគេយកប្រជាជនដែលជម្លៀសទៅព្រៃនាមហ្នឹងទៅ បាត់ដំបងទាំងអស់ អី ក៏តែម៉ាគ្រួសារលោកយាយទេ?

**ឃួនៈ** គេរំលែកតាមគ្រួសារ ។

**ឆៃវ៉ាន់ៈ** គេបែកតាមគ្រួសារ?

**ឃួនៈ** ចា៎ស! ណាមុខសញ្ញាទៅ ត្រង់ណាគេឲ្យទៅ ត្រង់ហ្នឹង បែកដូចថាយើងទៅកាន់ក្តាប់គេ ។

**ឆៃវ៉ាន់ៈ** នៅក្នុងស្រុកបាត់ដំបងហ្នឹងលោកយាយដឹងថាភូមិឃុំអីដែរអត់?

**ឃួនៈ** បែបជាក្នុងឃុំស្វាកែតមិនដឹង ។

**ឆៃវ៉ាន់ៈ** តែភូមិអីគេ?

**ឃួនៈ** ភូមិដាំស្ពៃ ។

**ឆៃវ៉ាន់ៈ** គេហៅភូមិដាំស្ពៃអញ្ចឹងហ្មង?

**ឃួនៈ** ចា៎ស! ខ្ញុំចាំថាភូមិដាំស្ពៃហ្នឹង ។

**ឆៃវ៉ាន់ៈ** នៅក្នុងស្រុកបាត់ដំបង,
កាលគេឲ្យគាត់ធ្វើនៅកន្លែងសហករណ៍ដាំស្ពៃហ្នឹងគាត់ធ្វើអីខ្លះទៅ យាយ?

**តុំៈ** គ្មានធ្វើអី ធ្វើគណៈសហករណ៍ ។

**ណៃវ៉ាន់ៈ** គណៈសហករណ៍ហ្នឹងការងារគាត់ធ្វើម៉េចខ្លះ?

**តុំៈ** មានតែដឹកនាំគេធ្វើការអីហ្នឹងណា៎ ធ្វើស្រែធ្វើអីហ្នឹង នាំគេទៅធ្វើស្រែភ្ជួរ ដឹកនាំគេធ្វើអីចឹង ឯង ។

**ណៃវ៉ាន់ៈ** ដូចថាគាត់ដឹកនាំឲ្យគេធ្វើចាប់ពីម៉ោងប៉ុន្មានទៅ?

**តុំៈ** មិនដឹងម៉ោងប៉ុន្មាន ។

**ឃួនៈ** កាលហ្នឹងព្រឹកតែម៉ោង៧ដល់ម៉ោង១១ ដូចតែសព្វថ្ងៃហ្នឹងដែរ ។

**ណៃវ៉ាន់ៈ** ព្រឹកឡើងម៉ោង៧នាំប្រជាជនទៅធ្វើទៅ?

**ឃួនៈ** ចា៎ស! ដល់ម៉ោង១១ឡើង ពេលបាយ ។

**ណៃវ៉ាន់ៈ** ហើយគាត់ធ្វើជាមួយគេដែរអត់?

**តុំៈ** ធ្វើ, ដឹកនាំគេអត់មានឈរមើលទេ ដឹកនាំគេធ្វើមុនគេហ្នង បើមិនអញ្ចឹងដឹកនាំប្រជាជនយើងទៅឈរមើលគេម៉េច ទាល់តែយើងហ្នឹងទៅធ្វើ ។

**ឃួនៈ** មានអ្នកខ្លះឈរមើលគេដែរ ។

**តុំៈ** អាណឹងមិនដឹងទេ បើគ្រួសារខ្ញុំអត់មានឈរមើលទេ ទៅមុនប្រជាជនទៀតធ្វើនោះ ។

**ណៃវ៉ាន់ៈ** គេហៅសហករណ៍ដាំស្ពៃអញ្ចឹង?

**តុំៈ** ចា៎ស! ដាំស្ពៃ ។

**ណៃវ៉ាន់ៈ** កាលហ្នឹងពីណាគេទៀតធ្វើការជាមួយគាត់នៅខាងសហករណ៍ហ្នឹង?

**តុំៈ** គេនៅស្រុកគេណោះ ខ្ញុំធ្វើការជាមួយ មិនចាំគេទេ ។

**ណៃវ៉ាន់ៈ** យាយមានស្គាល់ឈ្មោះគេទេ?

**តុំៈ** ឈ្មោះតាវ៉ង់ ។

**ណៃវ៉ាន់ៈ** តាវ៉ង់ហ្នឹងគាត់ឋានៈអីដែរ?

**ឃួនៈ** មិនដឹងឋានៈអីទេ ប៉ុនរងពីគាត់ហ្នឹងទៅ ។

**ណៃវ៉ាន់ៈ** អូហ៍! តាវ៉ង់ហ្នឹងគាត់តូចជាងតាក់ហ្នឹងទេ?

**តុំៈ** ចា៎ស! ក្រោម បើគ្រួសារខ្ញុំលើ ។

**ណៃវ៉ាន់ៈ** ចុះបន្ទាប់ពីតាវ៉ង់ហ្នឹងមានណាគេទៀត?

**តុំ:** អត់ទេ មានតែពីរនាក់ មានតែពីរនាក់ទេ ។

**ឃួន:** ប៉ុនតាវ័ន់ហ្នឹងឈ្មោះគាត់ថន ។

**ណៃវ៉ាន់:** តាវ័នហ្នឹងឈ្មោះថន?

**ឃួន:** ប្រពន្ធគាត់ ។

**ណៃវ៉ាន់:**

ដូចថាការងារខាងសហករណ៍ហ្នឹងក្រៅពីនាំប្រជាជនធ្វើស្រែហ្នឹងមាននាំទៅ ធ្វើអីទៀតទេ? ដូចថាជីកទំនប់ លើកប្រឡាយអីមានធ្វើអីចឹងអត់?

**តុំ:** អត់ផង ឲ្យទៅ ខាងភ្នូរខាងអីទេ អត់មានទៅ លើកទំនប់អីណាអត់មានទេ ។

**ណៃវ៉ាន់:** អញ្ចឹងម៉ាឆ្នាំទល់ម៉ាឆ្នាំចេះតែនាំគេភ្ជួរ ធ្វើស្រែចឹងទៅ ?

**តុំ:** ធ្វើទៅ ដល់រួចទៅ ដល់ខែច្រូតៗ ទៅ ខែភ្ជួរៗ ទៅ ។

**ណៃវ៉ាន់:** តែកាលហ្នឹងគាត់ធ្វើ ហើយគាត់ម៉ោនៅជុំគ្នាជាមួយ លោកយាយធម្មតាទេ?

**តុំ:** នៅជាមួយគ្នា ។

**ណៃវ៉ាន់:** ចុះកូន?

**ឃួន:** ខ្ញុំនៅតូចនៅជាមួយ ហើយទៅ នៅកន្លែងពេទ្យ គាត់យកខ្ញុំទៅដាក់កន្លែងពេទ្យ ។

**ណៃវ៉ាន់:** អញ្ចឹងនៅជុំគ្នាទាំងអស់, ដូចថាគាត់ត្រឡប់ម៉ោផ្ទះរាល់ថ្ងៃ ឬក៏យូរៗ បានម៉ោផ្ទះម្ដង?

**តុំ:** គាត់នៅផ្ទះហ្នឹងឯង ព្រឹកឡើងទៅស្ទូងទៅ ។

**ណៃវ៉ាន់:** កាលហ្នឹងដូចថាគាត់មានដឹកនាំគេធ្វើការយប់អីទេ?

**តុំ:** យប់ហ្នឹងដូចមិនឃើញធ្វើ ឃើញតែធ្វើថ្ងៃហ្នឹង ។

**ណៃវ៉ាន់:** ឃើញតែពេលថ្ងៃទេ?

**តុំ:** ហ្នឹងហើយដែលនាំគេទៅភ្ជួរទៅអីហ្នឹងទេ ។

**ណៃវ៉ាន់:** ចុះពេលបើករបបហូបចុកអី គាត់ហ្នឹងអ្នកបើកឲ្យអីក៏មានអ្នកផ្សេងគេ?

**ឃួន:** អត់ទេ មានកន្លែងគេផ្សេង គេបើកឲ្យម៉ោ គាត់គ្រាន់តែទៅស្រែ ។

**ណៃវ៉ាន់:** គាត់ទៅតែស្រែទេ, ចុះដូចថាគាត់ទៅស្រែហ្នឹង លោកយាយមានដែលឮថាឥឡូវគាត់ត្រូវគ្រប់គ្រងប្រជាជនធ្វើស្រែហ្នឹងម៉ាថ្ងៃឲ្យប៉ុណ្ណេះៗ អីគាត់មានធ្លាប់និយាយប្រាប់យាយទេ ?

**តុំៈ** អត់ផង គ្រាន់តែដឹកនាំគេធ្វើ ដល់ខែប្រូតមិនដឹងបានប៉ុន្មានអីប៉ុន្មានអីមិនដឹងដែរ ។

**នៃវ៉ាន់ៈ** តែគេមានកំណត់ទេ ម៉ាថ្ងៃហ្នឹងគេដឹកនាំឲ្យប្រូតបានប៉ុន្មានហិកតា ប៉ុន្មានអីហ្នឹងគេមានកំណត់ ទេ?

**តុំៈ** អត់មានកំណត់ គិតតែម៉ោង ។

**នៃវ៉ាន់ៈ** ចុះឧបមាថាយើងទៅស្ទូងអញ្ចឹង យើងខ្ជិលធ្វើការ យើងធ្វើលេងៗអញ្ចឹងបានដែរ?

**តុំៈ** គ្មានស្អី ឲ្យតែយើងទៅធ្វើ, គេមានទៅបង្ខំអីប៉ុន្មាន ដល់ម៉ោងទៅៗ ។

**នៃវ៉ាន់ៈ** អញ្ចឹងគាត់ដឹកនាំគេទៅធ្វើស្រែតែម៉ាមុខហ្នឹងទេ?

**តុំៈ** ចា៎ស! ដឹកនាំធ្វើស្រែតែម៉ាមុខ ។

**នៃវ៉ាន់ៈ** ចុះការហូបចុកអីយ៉ាងម៉េចដែរកាលហ្នឹង?

**តុំៈ** ការហូបចុកអីហ្នឹងហូបបបរអីដែរ ។

**នៃវ៉ាន់ៈ** បបរយើងដូចយើងហូបរាល់ថ្ងៃហ្នឹងដែរអីក៏ម៉េច?

**តុំៈ** បបរសាប, មានសម្លរមានអីហូប ។

**នៃវ៉ាន់ៈ** មានគ្រាប់អង្ករច្រើនដែរអត់?

**តុំៈ** មាន ។

**ឃួនៈ** តាមរដូវដែរ រដូវប្រាំងបាយទៅ រដូវវស្សាបបរ ។

**នៃវ៉ាន់ៈ** តែបានហូបឆ្អែតទេលោកយាយ?

**តុំៈ** ឆ្អែត ។

**នៃវ៉ាន់ៈ** អ្នកស្រុកផ្សេងទៀតឆ្អែតដែរអីក៏?

**តុំៈ** ប្រជាជននោះឆ្អែតដែរ ហូបបបរហ្នឹងក៏វាសល់ដែរមែនថាមិនឆ្អែតទេ វាមានសល់មានអី ។

**នៃវ៉ាន់ៈ** ចុះប្រធានសហករណ៍ហើយនិងប្រជាជនគេឲ្យរបបស្មើរគ្នាអីក៏ម៉េច?

**ឃួនៈ** មិនដឹងស្មើមិនស្មើ ខ្ញុំវិញទៅហូបកន្លែងកសិដ្ឋាន កន្លែងរួមដែរ ។

**នៃវ៉ាន់ៈ** ទៅហូបរួមដែរ, ចុះគាត់ទៅហូបជាមួយគ្នាទាំងអស់?

**ឃួនៈ** ចា៎ស! ប៉ុន្តែទៅហ្នឹងដូចថាម៉ាតុរហ្នឹងប៉ុន្មានវាល់ចែកគ្នាម៉ោ ណាសល់យកម៉ោផ្ទះម៉ោ ។

**នៃវ៉ាន់ៈ** អូហ៍! យកម៉ោផ្ទះបានដែរ?

**ឃួនៈ** បាន ឲ្យតែរបបយើងគេចែកទៅ យើងសល់ យើងយកម៉ោ ។

**ផៃរ៉ាន់:** អញ្ចឹងការហូបចុកអី នៅកន្លែងហ្នឹងអត់ពិបាកទេ?

**គុំ:** អត់សូវពិបាកទេនៅហ្នឹង ហូបបបរដែរតែវាមិនសូវពិបាកប៉ុន្មានទេ ។

**ផៃរ៉ាន់:** បានបបបរខាប់?

**គុំ:** ចា៎ស! ហូបឆ្អែត ។

**ផៃរ៉ាន់:** កាលហ្នឹងដឹងតែនៅក្នុងស្រុកបាត់ដំបងអញ្ចឹងហ្នងហេ៎?

**គុំ:** ចា៎ស!

**ផៃរ៉ាន់:** កាលហ្នឹងស្រុកបាត់ដំបងហ្នឹងគេហៅ ស្រុកលេខប៉ុន្មានដែរ?

**ឃួន:** មិនដឹងគេហៅ ស្រុកប៉ុន្មានទេ តំបន់បួនទីតំបន់៣ទេ ។

**គុំ:** តំបន់៤ ។

**ផៃរ៉ាន់:** តំបន់៤, តែស្រុកបាត់ដំបងហ្នឹងគេហៅ ស្រុកលេខប៉ុន្មាន?

**គុំ:** មិនដឹងស្រុកលេខប៉ុន្មានផង ។

**ផៃរ៉ាន់:** ដឹងតែតំបន់៤ មិនដឹងស្រុកលេខប៉ុន្មានទេ?

**ឃួន:** តំបន់បួន អត់ដឹងទេ ។

**ផៃរ៉ាន់:** ដូចថាភូមិហ្នឹងនៅឆ្ងាយពីទីរួមខេត្តទេ?

**ឃួន:** នៅចុះពីក្រុងបាត់ដំបងហ្នឹងទៅមិនឆ្ងាយប៉ុន្មានទេ នៅក្រោមស្ពឹងហ្នឹងប៉ុនថ្នល់ជាតិដែរ ។

**ផៃរ៉ាន់:** ចុះលោកយាយដូចថា គាត់គាត់ប្រធានសហករណ៍អីចឹងគាត់ខស្សាប្រជុំអីដែរអត់?

**គុំ:** ប្រជុំ ។

**ផៃរ៉ាន់:** ប្រជុំ គាត់ហៅ ប្រជាជនទាំងអស់ប្រជុំទៅ?

**គុំ:** ចា៎ស!

**ផៃរ៉ាន់:** លោកយាយអីចូលរួមប្រជុំដែរ?

**គុំ:** ចា៎ស!

**ផៃរ៉ាន់:** ភាគច្រើនប្រជុំហ្នឹងគេនិយាយពីអីទៅ?

**គុំ:** មិនចាំទេ ជំនាន់ហ្នុងម៉ោអត់ចាំទេ ។

**ផៃរ៉ាន់:** ចុះក្រៅពីគាត់ហៅ ប្រជុំហ្នឹង ដូចថាមានថ្នាក់ស្រុក ឬក៏តំបន់អីគេម៉ោប្រជុំជាមួយដែរ?

**គុំ:** ដូចជួនណាគេម៉ោ ជួនណាគេអត់ម៉ោ ។

**ផៃវ៉ាន់:** គេម៉ោហ្នឹងលោកយាយដឹងអ្នកដែលម៉ោហ្នឹងឈ្មោះអីទេ?

**ឃួន:** ស្គាល់តើ, គាត់ឈ្មោះឌឹក, សឹម, តាតែម ។

**ផៃវ៉ាន់:** ហ្នឹងម៉ោពីខាងណាម៉ោវិញ?

**ឃួន:** គេធ្វើធំអញ្ចឹង ប៉ុននៅពីក្រោម ។

**ផៃវ៉ាន់:** បាទ! ធ្វើធំអញ្ចឹងដូចថាគាត់នៅខាងស្រុកអីក៏នៅខាងតំបន់ឈ្មោះមិញហ្នឹង?

**ឃួន:** ស្រុក ខាងស្រុកតើ ។

**ផៃវ៉ាន់:** ឈ្មោះអីគេ?

**តុំ:** ឌឹក មួយ តែម មួយ តាសឹម មួយ ។

**ផៃវ៉ាន់:** បីនាក់ហ្នឹងណាគេធំជាងគេ?

**តុំ:** បីអ្នកហ្នឹងធំបីអង្គភាពគេ ។

**ផៃវ៉ាន់:** ណាគេធំជាងគេ?

**តុំ:** តាសឹមធំជាងគេ ។

**ផៃវ៉ាន់:** ពេលតាសឹម តាឌឹក តាតែមហ្នឹងគាត់ម៉ោប្រជុំ គាត់ម៉ោប្រជុំតែជាមួយពួកសហករណ៍ អីក៏គាត់ម៉ោប្រជុំជាមួយអ្នកស្រុកអ្នកភូមិធម្មតាដែរ?

**តុំ:** អ្នកស្រុកភូមិម្តងៗម៉ាយាមទេ ។

**ឃួន:** បើអ្នកធ្វើការគ្នាគាត់មិនដឹង មិនដឹងគាត់ទៅប្រជុំនៅណា បើម៉ោប្រជុំតាមភូមិហ្នឹងម្តងម៉ា យាម ។

**ផៃវ៉ាន់:** អញ្ចឹងខាងស្រុកគេធ្លាប់ចុះម៉ោប្រជុំដែរ?

**ឃួន:** តែម្តងម៉ាយាមទេ ។

**ផៃវ៉ាន់:** ចុះខាងតំបន់?

**ឃួន:** តំបន់អត់ស្គាល់ ។

**ផៃវ៉ាន់:** ចុះគាត់ហ្នឹងក្រោយម៉ោគេមានប្តូរតួនាទីគាត់ធ្វើអីទៀតដែរអត់?

**តុំ:** អត់មានប្តូរធ្វើអីទេ គាត់នៅកាន់គណៈសហករណ៍ហ្នឹង ។

**ឃួន:** ពីដើមម៉ោគាត់ដូចថាភូមិ ពីមុនកាលនៅភូមិដាំស្ពៃ ដល់ភូមិម៉ោគេតំឡើងគាត់ដូចជាមេឃុំ ។

ផៃវ៉ាន់៖ ប្រធានសហករណ៍ដូចមេឃុំអញ្ចឹង?

ឃួន៖ ចា៎ស! មុនដែលទៅ នៅហ្នឹងគាត់ត្រឹមភូមិទេ ។

ផៃវ៉ាន់៖ ហើយកាត់នៅកាន់ជាគណៈសហករណ៍ហ្នឹងរហូត?

តុំ៖ កាន់រហូត ទាល់តែគេចាប់ ។

ផៃវ៉ាន់៖ កាលហ្នឹងលោកយាយដឹងថាហេតុអីបានគេចាប់ទេ?

តុំ៖ អត់ដឹងផង ។

ឃួន៖ មូលហេតុខ្ញុំដឹងតិចៗ ដឹងថា ពីកាលហ្នឹងមានបក្សពួកវាពីរ ដល់ពេលគេថាមានពួកនិរតីម៉ា ជាន់ទៀតគេចាប់ពួកពុកខ្ញុំហ្នឹងពួកពាយ័ព្យ ។

ផៃវ៉ាន់៖ ពួកនិរតីចូលមកទៀត?

ឃួន៖ ចា៎ស! គេចាប់បញ្ចេញពួកពាយ័ព្យហ្នឹងទាំងអស់ ចូលនិរតីកាន់ក្តាប់វិញ ពួកនិរតីចូលម៉ោ បានខ្លាំងមែនទែន ។

ផៃវ៉ាន់៖ ឆ្នាំណាដែលពួកនិរតីចុះម៉ោយាយ?

ឃួន៖ ឆ្នាំ៧/៨ហ្នឹងឯង ។

ផៃវ៉ាន់៖ ដើមឆ្នាំអីក៏ចុងឆ្នាំ?

ឃួន៖ ប្រហែលដើមឆ្នាំ ។

ផៃវ៉ាន់៖ ពេលពួកនិរតីចុះម៉ោហ្នឹង, ដឹងថាមេដែលគេនាំចុះម៉ោហ្នឹងឈ្មោះអីទេ?

តុំ៖ អត់ស្គាល់ទេ មេឈ្មោះអីទេភ្លេចហើយ ។

ឃួន៖ ឈ្មោះតាឯក ។

ផៃវ៉ាន់៖ ឈ្មោះឯកខាងនិរតីហ្នឹង ចុះម៉ោ?

ឃួន៖ អ្នកបញ្ជាឲ្យចាប់ពុកខ្ញុំហ្នឹងឈ្មោះឯក ។

ផៃវ៉ាន់៖ ឯកហ្នឹងគាត់កាន់ខាងអីដែរ?

ឃួន៖ ខាងនិរតីប៉ុនមិនដឹងគេកាន់ខាងអី អ្នកបញ្ជាឲ្យចាប់ហ្នឹងឈ្មោះឯក ខ្លាំងជាងគេ ។

ផៃវ៉ាន់៖ កាលហ្នឹងគេចុះម៉ោគេចាប់ ផ្តើមចាប់ពីណាគេមុនពួកនិរតី?

ឃួន៖ ចាប់តាសឹមហ្នឹងមុន តាសឹមម៉ោតាតែម តាឋឹកហ្នឹង ។

ផៃវ៉ាន់៖ អូហ៍! គេចាប់ខាងស្រុកម៉ោមុន?

**ឃួនៈ** ពុកខ្ញុំចាប់ក្រោយគេ ។

**ឆៃរ៉ាន់ៈ** ហើយបន្ទាប់ម៉ោចាប់យុំ?

**ឃួនៈ** ចា៎ស! ប៉ុនចាប់ដែលស្រុកហ្នឹងចាប់យកទៅទាំងប្ដីទាំងប្រពន្ធ ដល់គេចាប់ពុកខ្ញុំហ្នឹងគេចាប់តែពុកខ្ញុំទៅ ម៉ែខ្ញុំអត់ ។

**ឆៃរ៉ាន់ៈ** ពួកស្រុកគេចាប់ទាំងប្ដីទាំងប្រពន្ធ?

**ឃួនៈ** ចា៎ស! ចាប់ដាក់ឡានទាំងអស់ ទាំងកូនទាំងអីទាំងអស់ ។

**ឆៃរ៉ាន់ៈ** អូហ៍! ម៉ាគ្រួសារហ្មង, តែបើយុំគេចាប់តែប្ដីទេ?

**ឃួនៈ** ចាប់ទាំងប្រពន្ធដែរ

ប៉ុនដូចថាសំណាងម៉ែខ្ញុំដូចគេយកតែពុកខ្ញុំទៅ បាននៅទល់សព្វថ្ងៃហ្នឹង ។

**ឆៃរ៉ាន់ៈ** ពេលគេចាប់ហ្នឹងគេភ្ជង់ចាប់យើងហ្មង អីក៏គេម៉ោហៅយើងថាទៅណាទៅណែអី?

**ឃួនៈ** ភ្ជង់ហ្មង ចាប់ឡើងឡានហ្មង ។

**ឆៃរ៉ាន់ៈ** យាយបានឃើញគេចាប់គាត់ទេ?

**តុំៈ** អត់ឃើញ បានតែគេប្រាប់ ។

**ឃួនៈ** ពុកខ្ញុំហ្នឹងគេហៅបញ្ចូលរោងម៉ាស៊ីន ឡានគេអាយ៉ៃចូលទៅក្នុងហ្នឹងគេចាប់ចងឡើង មានអេស្កកគេ ។

**ឆៃរ៉ាន់ៈ** ពីណាគេដែលម៉ោប្រាប់ថាឃើញចាប់ហ្នឹង?

**ឃួនៈ** អ្នកគេនៅរោងម៉ាស៊ីនហ្នឹង ។

**ឆៃរ៉ាន់ៈ** ឈ្មោះអីគេទៅ?

**ឃួនៈ** អត់ស្គាល់ទេ ភ្លេចបាត់អស់ហើយ ។

**ឆៃរ៉ាន់ៈ** ពួកនិរតីគេហៅចូលហើយគេចាប់យកទាំងអស់គ្នា?

**ឃួនៈ** ចា៎ស! ចាប់ចង ។

**ឆៃរ៉ាន់ៈ** គេចងម៉េច? ចងបិទមុខអីក៏ម៉េច?

**ឃួនៈ** ចងស្លាបសេក ដាក់អាឡានស្កុតតូចហ្នឹង ។

**ឆៃរ៉ាន់ៈ** ដូចថាពេលគេចាប់ភ្លាមហ្នឹងលោកយាយដឹងថាគេចាប់ហ្មង អីក៏ក្រោយម៉ោបានដឹង?

**តុំៈ** ល្ងាចឡើងបានដឹង ។

**ផៃវ៉ាន់**: លោកយាយដឹងថាហេតុអីបានគេចាប់ទេ?

**គុំ**: អត់ដឹងហេតុអីផងទេ ។

**ឃួន**: មូលហេតុដូចខ្ញុំប្រាប់ពូឯងអញ្ចឹងឯង ពួកនិរតីម៉ោគេកំចាត់ពួកពាយ័ព្យហ្នឹងចេញ ។

**ផៃវ៉ាន់**: ដូចថាគាត់ធ្វើអីខុសបានគេចាប់អីក៏ម៉េច?

**ឃួន**: ឲ្យតែពាយ័ព្យ ឲ្យតែពួកធ្វើការគេសំលេះចេញ គេដាក់និរតីចូលម្តង ។

**ផៃវ៉ាន់**: អញ្ចឹងដល់ពេលគេចាប់គាត់ហ្នឹងទៅ ពីណាដែលឡើងជំនួសគាត់ពួកនិរតី?

**ឃួន**: ពួកនិរតីតាឯកហ្នឹងហើយដែលកាន់ក្តាប់ហ្នឹងនោះ ។

**ផៃវ៉ាន់**: ឯកឡើងជំនួសវិញ? ចុះក្រៅពីឯកមានណាគេទៀតទេ?

**ឃួន**: ខ្ញុំអត់ស្គាល់គេទេ ខ្ញុំនៅតូចដែរ ។

**គុំ**: ស្គាល់តែឯកហ្នឹងម្នាក់ ។

**ផៃវ៉ាន់**: អញ្ចឹងឯកហ្នឹងឡើងជំនួស, ចុះដូចលោកយាយគ្រួសាររបស់គាត់អញ្ចឹង ដឹងថាគេចាប់ប្តីអញ្ចឹងដូចថា លោកយាយមានអារម្មណ៍ម៉េចទៅ?

**គុំ**: អារម្មណ៍ខ្លាច គេចាប់ប្តីហើយតែងតែខ្លាចគេយកប្រពន្ធទៀត មុនៗគេចាប់អញ្ចឹង គេយកប្តីគេចាប់ប្រពន្ធ ។

**ឃួន**: គាត់ឃើញគេអ្នកមុនៗគេចាប់អញ្ចឹងហើយ ។

**ផៃវ៉ាន់**: អញ្ចឹងមុនគេចាប់គ្រួសារលោកយាយមានគេចាប់អញ្ចឹងដែរ?

**ឃួន**: ចាប់ មុនហ្នឹងចាប់អញ្ចឹងទាំងអស់ ។

**ផៃវ៉ាន់**: ហ្នឹងខាងណាអ្នកម៉ោចាប់?

**ឃួន**: ខាងពួកខាងនិរតីហ្នឹងឯង ដូចថាគេរៀងឡើងគេចាប់ចេញអស់ ។

**ផៃវ៉ាន់**: ចុះមុននិរតីម៉ោ ដូចថាអ្នកធ្វើការជាមួយយាយ ឬក៏អ្នកស្រុកភូមិហ្នឹងមានគេចាប់ដែរអត់?

**ឃួន**: ពីមុនហ្នឹងអត់មានចាប់ផង ដល់និរតីចូលម៉ោ ។

**ផៃវ៉ាន់**: កាលមុនិរតីចូលម៉ោហ្នឹងអត់មានទេ?

**គុំ**: អត់មានទេ អត់មានណាចាប់អីទេ ។

**ផៃវ៉ាន់**: ការងារក៏អត់សូវពិបាកដែរ?

**គុំៈ** ចា៎ស! មានតែពួកនិរតីហ្នឹងឯងម៉ោចាប់ ។

**ឆៃរ៉ាន់ៈ** ពេលពួកនិរតីម៉ោហ្នឹងដូចជាការងាររគេផ្លាស់ប្តូរម៉េចទៅ ?

**ឃួនៈ** លត់ដីខ្លាំងដែរហ្នឹងណា៎ ។

**ឆៃរ៉ាន់ៈ** លត់ដីម៉េច?

**ឃួនៈ** ទៅ ធ្វើការអីគ្រុនអីតិចតួចមិនឲ្យឈប់មិនឲ្យសម្រាកអីដែរហ្នឹងណា៎ ។

**ឆៃរ៉ាន់ៈ** ពួកនិរតីហ្នឹងពួកម៉ោពីខាងណាវិញ?

**គុំៈ** មិនដឹងម៉ោពីណា, បើគេហៅពួកនិរតី មិនដឹងម៉ោពីខាងណា ។ ស្រុកកើតណោះស្រែអំបិល ពួកនិរតីរឌីនៗ សុទ្ធតែដើងខោប៉ុណ្ណេះៗ, និយាយរឌីនៗ ។ ខាងតាកែវហ្នឹងឯង ។

**ឆៃរ៉ាន់ៈ** កាលហ្នឹងស្គាល់ប្រធានភូមិភាគនិរតីហ្នឹងណាគេទេ?

**គុំៈ** អត់ស្គាល់ផង ។

**ឆៃរ៉ាន់ៈ** ចុះនិយាយខាងស្រុកហ្នឹង ខាងស្រុកតាសឹម តាអីហ្នឹង ពេលចាប់តាសឹមហ្នឹងណាគេឡើងជំនួសគាត់វិញ?

**ឃួនៈ** អាកន្លែងគាត់នៅដូចជាឆ្ងាយដែរ ខ្ញុំនៅតូចៗដូចជាអត់ដឹង រាប់គីឡូដែរហ្នឹង ។

**គុំៈ** កាលដែលគេចាប់ទៅមិនដឹងគេចាត់ណាដាក់ទៀតអត់ដឹងផង ។

**ឃួនៈ** បានចាប់ម៉ាសាររហ្នឹងបាត់ទាំងអស់, អត់មាននៅទេ នៅតែប្រពន្ធ ។

**ឆៃរ៉ាន់ៈ** ពេលពួកនិរតីម៉ោដូចជាការងាររគេកំណត់ឲ្យយើងធ្វើម៉េចទៅ ?

**ឃួនៈ** ធ្វើដូចម៉ោងអញ្ចឹងដែរ ប៉ុនគេរឹបអូសខ្លាំង ដូចជាមានឈឺបន្តិចបន្តួចអីគេអត់អាចឲ្យយើងឈប់បានទេ ទាល់តែវារបណ្តោយហ្នឹង ហើយយើងទៅមិនទាន់ម៉ោងក៏គេលត់យើងដែរ ផ្តាច់របបយើង បើឈឺល្មមៗយើងអត់ទៅ គេអត់ឲ្យរបបយើងហូបទេ ។

**ឆៃរ៉ាន់ៈ** ចុះកាលមុនពួកនិរតីម៉ោដូចជាយើងឈឺអីយើងអាចឈប់បាន?

**ឃួនៈ** យើងសុំច្បាប់ យើងទៅដេកពេទ្យដេកអី ។

**ឆៃរ៉ាន់ៈ** សុំច្បាប់អញ្ចឹងគេឲ្យរបបយើងធម្មតាអីក៏ម៉េច?

**ឃួនៈ** របបយើងធម្មតា បែកពេល ។

**ឆៃរ៉ាន់ៈ** ដូចជាមុនពេលពួកនិរតីម៉ោ យើងឈឺអញ្ចឹងយើងអាចសុំច្បាប់ឈប់បានប៉ុន្មានថ្ងៃ?

**តុំ:** ម៉ាអាទិត្យអី រឿងឃើញយើងដើររឹងអីគេឲ្យយើងធ្វើការ ។

**នៃវ៉ាន់:** បើពួកនិរតីអត់ទេ?

**ឃួន:** និរតីទាល់តែយើងងើបមិនរួចបណ្ដោយហ្នឹង............

វីដេ ៣

**នៃវ៉ាន់:** ពេលពួកនិរតីចូលម៉ោហូបចុកអីពិបាកហ៎?

**តុំ:** គេហូបច្រើនអត់ឆ្អែត ។

**នៃវ៉ាន់:** គេឲ្យហូបម៉េចទៅពួកនិរតី?

**តុំ:** ចែកបបរ ចែកតាមគុរយើង បបររាវទៅជារាវអត់មានខាប់ ។

**ឃួន:** ដូចថាបបររាវទៅជារាវអត់មានជាតិបាយ ។

**នៃវ៉ាន់:** ហ្នឹងបបររហូត អត់មានបាយ?

**តុំ:** ចា៎ស!

**ឃួន:** មានតែពេលចូលឆ្នាំអីបានមានបាយ ។

**នៃវ៉ាន់:** អូហ៍! ចូលឆ្នាំដែរ?

**ឃួន:** ចា៎ស! ខែចូលឆ្នាំគេឲ្យបាយម៉ាថ្ងៃអញ្ចឹងទៅ ។

**នៃវ៉ាន់:** ចុះភ្ជុំអី?

**ឃួន:** ភ្ជុំមាន ។

**នៃវ៉ាន់:** ចុះមានដែលពុកអាគេហៅថ្ងៃ១០ថ្ងៃ២០អត់?

**ឃួន:** ណឹងហើយអាថ្ងៃភ្ជុំហ្នឹងហើយ ។

**នៃវ៉ាន់:** អញ្ចឹងឲ្យតែថ្ងៃ១០ថ្ងៃ២០ហ្នឹងគេឲ្យបាយយើងដែរ?

**ឃួន:** ឲ្យតែម៉ារដូវ ដូចថាម៉ារដូវខែភ្ជុំ ហើយខែចូលឆ្នាំ ។

**តុំ:** រួចពីហ្នឹងទៅបបររហូត ។

**នៃវ៉ាន់:** ពេលហ្នឹងដូចថាការចាប់មនុស្ស ការចាប់អីមានច្រើនទេ មានដែលឃើញគេចាប់មនុស្សអីទេពេលពួកនិរតីចូលម៉ោណា៎?

**ឃួន:** ខាងហ្នឹង ពេលនិរតីចូលម៉ោដូចមិនសូវមានដែរទេ ប៉ុនគ្រាន់តែថា យ៉ាប់ហូបចុក ។

**ផៃរ៉ាន់:** តែចាប់អីអត់ទេ, អ្នកស្រុកអ្នកភូមិអីអត់បាត់ទេ?

**ឃួនៈ** បើថាគេវៃយើងវៃដូចថាយើងទៅលួចហូបមិនឆ្អែតអី គេចាប់បានគេវៃយើងហើយ ។

**ផៃរ៉ាន់:** គេវៃដែរ?

**ឃួនៈ** ចា៎ស!

**ផៃរ៉ាន់:** គេយកអីវៃទៅ?

**ឃួនៈ** ដំបង, បើគេមានកាំភ្លើងនៅនឹងដៃគេវៃនឹងកាំភ្លើងហ្នឹងឯង បើថាមានពួកឈ្លបគេមានកាំភ្លើងគេវៃនឹងកាំភ្លើងហ្នឹងឯង ។

**ផៃរ៉ាន់:** ចុះដូចថាលោកយាយ
ឬក៏មឹងពេលដែលយើងដូចថាជាប់ប្ដីគេចាប់អញ្ចឹងដូចថាមានកងឈ្លប
គេម៉ោតាមស៊ើបយើងជាប់អីក៏អត់អីទេ?

**គុំ:** កងឈ្លបអត់ម៉ោផង មានប៉ុនគេអត់ម៉ោ ។

**ផៃរ៉ាន់:** អត់មានម៉ោតាស៊ើបលោកយាយទេ?

**គុំ:** អត់ទេ ។

**ផៃរ៉ាន់:** អញ្ចឹងគេចាប់តែប្ដីទៅទេ ប្រពន្ធកូនគេអត់រវល់ទេ?

**គុំ:** អត់ទេ ។

**ឃួនៈ** ប៉ុនផុតពីហ្នឹងគេសុទ្ធតែចាប់ដាក់ទាំងអស់ដែរ ចាប់ទាំងកូនទាំងអី ។

**គុំ:** ពីជំនាន់មុនខ្ញុំគេចាប់ទាំងកូនទាំងប្រពន្ធទាំងអស់ ។

**ផៃរ៉ាន់:** ចុះយាយមានដឹងគេចាប់គ្រួសារលោកយាយបញ្ជូនទៅណាដែរអត់?

**គុំ:** អត់ដឹង, គេចាប់ទៅមិនដឹងគេយកទៅណា គេចាប់ពីផ្ទះទៅអត់ដឹងគេយកទៅណា ។

**ផៃរ៉ាន់:** ពេលគេចាប់គ្រួសារលោកយាយអញ្ចឹងក្នុងចិត្តហ្នឹងលោកយាយភ័យអញ្ចឹងដែរ?

**គុំ:** ចា៎ស! ភ័យ ។

**ផៃរ៉ាន់:** ចុះការរស់អីលោកយាយខំអីម៉េចដែរ?

**ឃួនៈ** ពេលហ្នឹងគាត់ទើបតែទម្លាក់ចង្រ្កានបានប៉ុន្មានថ្ងៃ ។

**ផៃរ៉ាន់:** បានប៉ុន្មានខែគេចាប់គាត់?

**គុំ:** បាន១២ថ្ងៃទម្លាក់ចង្រ្កាន ។

**ណៃវ៉ាន់**: កូនស្រីកូនប្រុស?

**គុំ**: កូនស្រី ។

**ណៃវ៉ាន់**: កាលហ្នឹងពេលឆ្លងទន្លេអញ្ចឹងគេបញ្ជូនយើងទៅ ពេទ្យអីត្រឹមត្រូវដែរអីក៏យ៉ាងម៉េច?

**គុំ**: ពេទ្យគេម៉ោ ។

**ណៃវ៉ាន់**: មានឆ្មបគេម៉ោបង្កើត?

**គុំ**: ឆ្មបគេនៅកន្លែងហ្នឹងមាន ។

**ណៃវ៉ាន់**: ដូចថាគេយកចិត្តទុកដាក់យើងទេពេលបង្កើត?

**ឃួន**: យកចិត្តទុកដាក់ដែរហ្នឹងណា៎ មានមុខអ្នកធ្វើការ ។

**ណៃវ៉ាន់**: គេខ្វាចយើងដែរ?

**ឃួន**: ចា៎ស!

**ណៃវ៉ាន់**:

ចុះលោកយាយពេលពួកនិរតីចូលម៉ោអញ្ចឹងគេអត់មានជម្លៀសឲ្យយើងទៅ នៅកន្លែងណា ផ្សេងទេ?

**គុំ**: ជម្លៀស គេឲ្យខ្ញុំទៅ នៅភ្នំតូច ។

**ណៃវ៉ាន់**: ភ្នំតូចណាវិញ?

**គុំ**: ទៅហួសបាត់ដំបងណោះ ទៅតាមមង្គលបូរី ។

**ណៃវ៉ាន់**: នៅក្នុងស្រុកមង្គលបូរី?

**ឃួន**: មិនដឹងនៅក្នុងស្រុកអីទេ ប៉ុនដឹងតែភ្នំតូច នៅជើងភ្នំតូចហ្នង ។

**ណៃវ៉ាន់**: ទៅធ្វើអីនៅហ្នឹង?

**គុំ**: ទៅហ្នឹងគេអត់ឲ្យយើងនេះណា៎ ទៅដល់ដកស្ទូងគេទៅ កូនតូចក៏ ។

**ណៃវ៉ាន់**: ពេលយើងទៅធ្វើការយើងយកកូនទៅដែរអីក៏មានអ្នកមើល?

**គុំ**: គេមើលឲ្យ ។

**ណៃវ៉ាន់**: អូហ៍! មានគេមើលឲ្យ ចុះបៅអីបានអីបៅទៅ?

**គុំ**: បៅដោះគេអ្នកមើលហ្នឹង បញ្ចុកឲ្យវាស៊ីទៅ ខ្ញុំចេះតែទៅវាស់ៗល្ងាចទៅ ពេលម៉ោវិញបានបៅដោះម៉ែ ។ មានគេដាក់មើលកុមារម៉ាកន្លែងទៅ ម៉ែៗវាទៅធ្វើស្រែអស់ទៅ ។

ឆៃវ៉ាន់: ចុះលោកយាយកាលហ្នឹងម៉េចបានគេជម្លៀសលោកយាយទៅខាងភ្នំតូចហ្នឹងវិញ?

ឃួនៈ អត់ដឹង គេជម្លៀសទៅៗខ្លាចគេដែរ គេដឹកឡានទៅ ។

ឆៃវ៉ាន់: អត់ដឹង, ទៅតែគ្រួសារយាយអីក៏ទៅទាំងអស់គ្នា?

គុំ: ទៅទាំងខ្ញុំទាំងអីហ្នឹង ។

ឆៃវ៉ាន់: ចុះមានអ្នកផ្សេងទៅទេ?

ឃួនៈ មាន ។

ឆៃវ៉ាន់: កាលហ្នឹងទៅប្រហែលប៉ុន្មានគ្រួសារទៅ ?

ឃួនៈ មិនដឹងប៉ុន្មានទេ ដឹកឡានទៅច្រើនដែរ មែនដាក់តែភ្នំតូចទេ ដាក់គ្រប់កន្លែង ។

ឆៃវ៉ាន់: គេដើរចែក?

ឃួនៈ ដាក់តាមភូមិគ្រប់កន្លែង ។

ឆៃវ៉ាន់: ទៅដល់ហ្នឹងយើងធ្វើស្រែចំការដូចនៅនេះអញ្ចឹង?

គុំ: ទៅដល់នោះយើងដកស្ទូងទៅ គ្មានឲ្យយើងនៅចាំទំនេរទេ គេធ្វើអីធ្វើហ្នឹងគេ ។

ឆៃវ៉ាន់: ចុះយប់គេឲ្យធ្វើអត់?

គុំ: យប់អត់ទេ ធ្វើតែថ្ងៃទេ ។

ឆៃវ៉ាន់: អញ្ចឹងលោកយាយគេជម្លៀសទៅភ្នំតូចហ្នឹង ចុះការហូបចុកអីស្រួលអីក៏ពិបាក?

គុំ: ពិបាក ហូបបាយហូបអីដែរ ។

ឆៃវ៉ាន់: បានហូបបាយដែរ, ស្រួលជាងកាលនៅបាត់ដំបង?

ឃួនៈ ពិបាកជាង ។

ឆៃវ៉ាន់: ពិបាកជាងលើការងារ អីក៏ពិបាកលើការហូបចុក?

ឃួនៈ ការងារក៏ពិបាក ហូបចុកក៏ពិបាកដែរ ។

ឆៃវ៉ាន់: អញ្ចឹងពិបាកជាងកាលយើងនៅបាត់ដំបង?

ឃួនៈ ចា៎ស! ពិបាកជាង ។

ឆៃវ៉ាន់: បានបាយហូបអីក៏បបរ?

ឃួនៈ មានពេលបាយបបរដែរ ប៉ុនដូចគេចែកតិចៗណា៎ពូ ។

ឆៃវ៉ាន់: ហូបអត់ឆ្អែត?

ឃួន: ចាស!

នៃវ៉ាន់: ចុះមានដែលឃើញអ្នកធ្វើការដែលកំពុងតែធ្វើៗ ហើយហូបអត់ឆ្អែត អស់កម្លាំងហើយស្លាប់ នៅកន្លែងធ្វើការហ្នឹងដែលឃើញទេយាយ?

តុំ: អត់ដែលទេ ។

ឃួន: ប៉ុនអ្នកធ្វើការអញ្ចឹងយើងទៅលួចអី ដូចនៅខាងភ្នំតូចហ្នឹងគេឲ្យយើងអូសនង្គ័លអីដែរហ្នឹង ។

នៃវ៉ាន់: អូហ៍! តែយើងលួចអញ្ចឹងគេឲ្យយើងអូសនង្គ័ល?

ឃួន: គេដាក់ទារុណកម្ម គេអូសរួចគេវ៉ៃយើង ។

នៃវ៉ាន់: ចុះគេមានចាប់យកទៅសម្លាប់យកទៅអីទេ?

ឃួន: យកទៅសម្លាប់យើងអត់បានឃើញដែរ ប៉ុនបាត់ៗមនុស្សប៉ុនមិនដឹងគេយកទៅសម្លាប់ណា ដែរមិនដឹង ។

នៃវ៉ាន់: ស្គាល់ទេអ្នកដែលបាត់ហ្នឹងឈ្មោះអីខ្លះ?

ឃួន: អត់ស្គាល់ទេ ទើបតែទៅអត់ស្គាល់គេ ។

នៃវ៉ាន់: អញ្ចឹងចំណាំឃើញអ្នកធ្វើការជាមួយគ្នាហ្នឹងបាត់ខ្លួនដែរ?

តុំ: ទេ ដូចអត់មានឃើញបាត់ ។

ឃួន: ខ្ញុំនៅកុមារបាត់ ខ្ញុំដល់ពេលនោះគេយកខ្ញុំទៅបែកពីគាត់ដែរ, ខ្ញុំនៅកុមារផ្សេង ។

នៃវ៉ាន់: ចុះមីងមានដែលឃើញគេចាប់ចង?

ឃួន: អត់ដែលឃើញទេអញ្ចឹងនោះ អត់ដែលឃើញទេ បើខ្ញុំនៅកុមារ វាអត់ឆ្អែតអីគេឲ្យទូល ស្រូវអញ្ចឹង វាលួចស្រូវដឹស៊ីអញ្ចឹងគេតាមទាន់គេចាប់បញ្ចូកស្រូវហ្នឹងតាមមាត់អីដែរ ។

នៃវ៉ាន់: ចុះមីងឈ្មោះអីដែរ?

ឃួន: ខ្ញុំឈ្មោះគាក់ ឃួន ។

នៃវ៉ាន់: អាយុប៉ុន្មានហើយ?

ឃួន: អាយុ៤០គត់ហើយ ។

នៃវ៉ាន់: ឆ្នាំខ្មែរមីងកើតឆ្នាំអី?

ឃួន: ឆ្នាំមមែ ។

**ណៃរ៉ាន់៖** សព្វថ្ងៃមីងរស់នៅក្នុងភូមិឃុំជាមួយគ្នាហ្នឹងដែរ?

**ឃួន៖** ចា៎ស!

**ណៃរ៉ាន់៖** នៅភូមិស្ដីហ្នឹងដែរ?

**ឃួន៖** ចា៎ស! មាននៅតែខ្ញុំមួយហ្នឹងឯង ពីរងាប់អស់មួយ ។

**ណៃរ៉ាន់៖** នៅ គេជម្លៀសនៅភ្នំតូចហ្នឹងរហូតដល់វៀតណាមចូល?

**តុំ៖** ដល់វៀតណាមចូល ។

**ឃួន៖** វៀតណាមចូលបានដើរម៉ោនៅភូមិដាំស្ពៃវិញ ។

**តុំ៖** ខ្ញុំកុំបានវៀតណាមរំដោះខ្ញុំត្រូវងាប់នៅ នោះហើយ ។

**ណៃរ៉ាន់៖** ម៉េចអញ្ចឹងយាយ?

**តុំ៖** ស្អែកឡើងយាយឯងកុំទៅណា គេអត់ឲ្យទៅណាទេ ដល់យប់ឡើងសភាពការណ៍មិនស្រួល ព្រឹកឡើងវៀតណាមម៉ោដល់ខ្ញុំរួចខ្លួន ។

**ណៃរ៉ាន់៖** ម៉េចដឹងថាគេបម្រុងយកយាយទៅ?

**តុំ៖** គេប្រាប់ថា កុំឲ្យយាយឯងទៅណា ស្អែកឡើងទៅលាន ។

**ណៃរ៉ាន់៖** គេឲ្យទៅណា?

**តុំ៖** គេឲ្យទៅ ធ្វើការកន្ទែងលានរាល់តែថ្ងៃ ដល់ថ្ងៃហ្នឹងគេប្រាប់ខ្ញុំថាយាយឯងកុំទៅណាស្អែក ណា៎ គេអត់ឲ្យខ្ញុំទៅណាទេ ។

**ណៃរ៉ាន់៖** អាណឹងពេលជិតវៀតណាមចូលហ្នឹងហោ៎?

**តុំ៖** ដល់ព្រឹកឡើងវៀតណាមម៉ោដល់ខ្ញុំរួចខ្លួនខ្ញុំ កុំអីខ្ញុំងាប់ហ្នុងបាត់ហើយ ។

**ណៃរ៉ាន់៖** អ្នកដែលម៉ោប្រាប់លោកយាយថាកុំឲ្យទៅណាហ្នឹងឈ្មោះអីទៅ?

**តុំ៖** ឈ្មោះតាម៉ុយ ។

**ណៃរ៉ាន់៖** តាម៉ុយហ្នឹងគាត់តួនាទីអី?

**តុំ៖** មិនដឹងអីទេ ។

**ណៃរ៉ាន់៖** ពេលគេជម្លៀសប្រជាជនពីភូមិដាំស្ពៃហ្នឹង ឯកហ្នឹងទៅជាមួយដែរអីក៏?

**ឃួន៖** អត់ទេគាត់នៅ ខាងមន្ទីរបាត់ដំបងណោះ ។

**ណៃរ៉ាន់៖** ទៅដល់ណោះតាម៉ុយអ្នកកាន់?

**ឃួនៈ** គាត់កាន់ក្តាប់តែម៉ាក្នុងភូមិទេគាត់ហ្នឹងនោះ ។

**ឆៃវ៉ាន់ៈ** គាត់ហ្នឹងដែលម៉ោប្រាប់យាយថាអញ្ជើង?

**គុំៈ** ចា៎ស!

**ឆៃវ៉ាន់ៈ** លោកយាយមានដឹងទេថាម៉េចបានគេម៉ោប្រាប់ថាអញ្ជើង?

**គុំៈ** អត់ដឹងមូលហេតុ ។

**ឆៃវ៉ាន់ៈ** តែលោកយាយចំណាំថាតែគេម៉ោប្រាប់អញ្ជើងមានន័យថាគេយកទៅសម្លាប់អីក៏ម៉េច?

**គុំៈ** អត់ដឹងផង មិនឲ្យធ្វើការមិនដឹងគេឲ្យទៅណា ។

**ឃួនៈ** ដឹងតែបាត់ខ្លួន ដឹងតែថាគេអត់ឲ្យធ្វើការមានតែគេអញ្ជើងឯង ។

**ឆៃវ៉ាន់ៈ** ចុះអ្នកមុនៗ គេម៉ោនិយាយប្រាប់អញ្ជើងដែរ?

**គុំៈ** គេម៉ោប្រាប់ម៉ាថ្ងៃហ្នឹង យប់ឡើងស្រាប់ល្ងាចហ្នឹងវៀតណាមម៉ោដល់ ។

**ឆៃវ៉ាន់ៈ** បាទ! តែអ្នកផ្សេងទៀតពេលគេម៉ោប្រាប់អញ្ជើងហើយ បន្ទាប់ម៉ោបាត់ខ្លួនអីក៏ម៉េច?

**គុំៈ** មិនដឹងគេទៅណាអស់ទៅ ។

**ឆៃវ៉ាន់ៈ** អូហ៍! គេម៉ោប្រាប់អញ្ជើងដូចគ្នា ដល់ហើយបាត់ខ្លួនលែងឃើញម៉ោអញ្ជើងទៅ?

**គុំៈ** ចា៎ស!

**ឆៃវ៉ាន់ៈ** ដល់ពេលលោកយាយចំណាំ ដល់ពេលម៉ោដល់ខ្លួន ពេលគេម៉ោប្រាប់អញ្ជើងមានអារម្មណ៍ម៉េចទៅ?

**គុំៈ** ភ័យ ។

**ឆៃវ៉ាន់ៈ** អត់សុំគេបានទេកាលហ្នឹង?

**គុំៈ** អត់ ។

**ឆៃវ៉ាន់ៈ** អញ្ជើងបានម៉ាថ្ងៃវៀតណាមចូលម៉ោ?

**គុំៈ** ចា៎ស! ប្រាប់ខ្ញុំល្ងាចហ្នឹងថាយាយឯងស្អែកឡើងកុំឲ្យទៅលានណា ដល់ព្រឹកឡើងវៀតណាម ម៉ោដល់ទឹប ។

**ឃួនៈ** ពួកគេប្រាប់ថា ឃើញរទេះភ្លើងបើកកាត់ហ្នឹងសុទ្ធតែឈាម ប្រឡាក់សុទ្ធតែឈាម ។

**ឆៃវ៉ាន់ៈ** រទេះភ្លើងបើកកាត់ណា?

**ឃួនៈ** ខ្ញុំនៅហ្នឹងជិតថ្នល់រទេះភ្លើងហ្នឹងដែរ នៅជើងភ្នំនោះ ភ្នំតូច ថ្នល់រទេះភ្លើងគៀនភ្នំហ្នឹងឯង ។

**ណៃវ៉ាន់ៈ** ប្រលាក់សុទ្ធតែឈាមម៉េច?

**ឃួនៈ** បើកកាត់ប្រឡាក់អាទ្វារ ។

**ណៃវ៉ាន់ៈ** ពេលវៀតណាមចូលហ្នឹងហ៎?

**ឃួនៈ** ចា៎ស!

**ណៃវ៉ាន់ៈ** ពេលវៀតណាមចូល យាយហើយនិងមីងអីគេជម្លៀសទៅដល់ណាទៅ?

**ឃួនៈ** ខ្ញុំម៉ោខ្លួនឯងម៉ោភូមិដាំស្ពៃនេះវិញ ។

**ណៃវ៉ាន់ៈ** គេអត់គៀរទៅជាមួយគេទេអញ្ចឹង?

**ឃួនៈ** អត់ទេ ម៉ោតាមថ្នល់ហ្នឹងម៉ោវិញ ។

**ណៃវ៉ាន់ៈ** ចុះឆ្នាំណាបានម៉ោដល់ភូមិស្រុកនេះវិញ?

**ឃួនៈ** ម៉ោ៧៩ម៉ោស្រុកនេះវិញ ម៉ោហ្នឹងមាខ្ញុំ ប្អូនគាត់ហ្នឹងទៅយកម៉ោ ។

**ណៃវ៉ាន់ៈ** ចុះប្អូនស្រីមួយស្លាប់ហ្នឹងស្លាប់ឆ្នាំណា?

**ឃួនៈ** ស្លាប់៧៩ ពេលរត់ហ្នឹង ។

**ណៃវ៉ាន់ៈ** ថីបានស្លាប់?

**ឃួនៈ** លាប់កញ្ជ្រិល ។

**ណៃវ៉ាន់ៈ** អញ្ចឹងម៉ោដល់ភូមិឃុំនេះ៧៩, ពេលលោកយាយម៉ោដល់ស្រុកភូមិនេះវិញលោកយាយបាត់បង់សាច់ញាតិបងប្អូនអស់ប៉ុន្មាននាក់ដែរ?

**គុំៈ** អត់មានទេ ។

**ឃួនៈ** មានអ៊ំខ្ញុំម្នាក់គេចាប់ ។

**ណៃវ៉ាន់ៈ** ហើយនិងឪពុកមីងម្នាក់?

**ឃួនៈ** ចា៎ស! អ៊ំខ្ញុំហ្នឹងគេចាប់យកទៅសម្លាប់ចោល នេះសល់កូនគាត់ ។

**ណៃវ៉ាន់ៈ** ចុះដូចថា លោកយាយធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមអញ្ចឹង យាយយល់ថាសម័យខ្មែរក្រហមហ្នឹងជាសម័យម៉េចដែរ?

**ឃួនៈ** សម័យវេទនា ។

**នៃរ៉ាន់:** វេទនាម៉េចខ្លះ?

**ឃួន:** វេទនាហូបចុកអីសព្វគ្រប់អីចឹងទៅ វាមិនបានសប្បាយ សេរីភាពដូចសព្វថ្ងៃ ។

**នៃរ៉ាន់:** ពិបាកតែហូបចុកទេ?

**ឃួន:** ហូបចុក ពិបាកកម្លាំងអីហ្នឹង កម្លាំងធ្វើអីហ្នឹង គ្មានសេរីភាពដូចសព្វថ្ងៃណា ។

**នៃរ៉ាន់:** ចុះក្រៅពីពិបាកហូបចុក ពិបាកកម្លាំងហ្នឹងមានពិបាកអីផ្សេងទៀតអត់?

**ឃួន:** គ្មានពិបាកអី ពិបាកតែរឿងហូបចុក ពិបាកកម្លាំង ពិបាកចិត្តហ្នឹងឯង ។

**នៃរ៉ាន់:** ពិបាកចិត្តរឿងអី?

**ឃួន:** ពិបាកចិត្តរឿងខ្លាចគាប់ហ្នឹងឯង យើងហូបមិនឆ្អែតគេធ្វើបាបទៅ ។

**នៃរ៉ាន់:** ចុះម៉េចពិបាកចិត្តខ្លាចស្លាប់ បើមិនដែលឃើញគេសម្លាប់ផង?

**ឃួន:** ចុះមានទៅ ឃើញសម្លាប់អី មានឃើញបាត់នឹងគេដែរ ប៉ុនមិនដឹងបាត់យកទៅណា គេមែន យកម៉ោសម្លាប់ឲ្យយើងឃើញនៅមុខហ្នឹងណ៎ា គ្រាន់តែបាត់ ។

**នៃរ៉ាន់:** អញ្ចឹងដូចថាធ្លាប់និយាយរឿងសម័យខ្មែរក្រហមហ្នឹងឲ្យកូនចៅអីស្តាប់ដែរអត់?

**ឃួន:** និយាយតើ ។

**នៃរ៉ាន់:** និយាយថាម៉េចខ្លះ?

**ឃួន:** និយាយថា កូនអីរាល់ថ្ងៃនេះវាមិនទាន់សម័យពិបាកខ្លួនឯងពីជំនាន់ហ្នុងណ៎ា ។

**នៃរ៉ាន់:** ប្រាប់ទៅកូនជឿដែរអត់?

**ឃួន:** វាមិនជឿទេ វាមិនដឹង វាមិនឃើញ ។

**នៃរ៉ាន់:** កូនថាអត់ជឿអញ្ចឹងហ្នុង?

**ឃួន:** ទេវាមិនថាទេ វាអង្គុយស្តាប់អត់សួរដឹងថាពិបាកវេទនា ប៉ុនក្នុងចិត្តវាមិនឃើញ វាមិនដឹង នោះ វាមិនជឿ ។

**នៃរ៉ាន់:** អញ្ចឹងមីងរាល់ថ្ងៃនេះដូចថាធ្លាប់ព្ត៌មានតាមវិទ្យុ តាមទូរទស្សន៍ តាមកាសែតអីពីការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរអត់?

**ឃួន:** ខ្ញុំមិនដែលបើក អត់មានវ៉ាឌីយ៉ូអីផងខ្ញុំ ។

**នៃវ៉ាន់:**

ចុះដែលពុអ្នកភូមិហ្នឹងនិយាយគ្នាអីថាគេបង្កើតតុលាការកាត់ទោសខ្មែរក្រហមៗអីដែលពុគេ និយាយទេ?

**ឃួនៈ** ហ៎! ពុដែរតែមិនដឹងគេកាត់ទោសខ្មែរក្រហមម៉េចៗ

**នៃវ៉ាន់:** ពុតាមរយៈអីទៅ?

**ឃួនៈ** ពុតែគេប្រជុំកាត់ទោសខ្មែរក្រហមហ្នឹង ប៉ុនមិនដឹងគេកាត់ទោសម៉េចៗ

**នៃវ៉ាន់:** ចុះមីងយល់ម៉េចដែរពុថាគេកាត់ទោសៗអញ្ចឹង?

**ឃួនៈ** នឹកឃើញខឹងពីការលំបាកវេទនាដែរហ្នឹងៗ

**នៃវ៉ាន់:** អញ្ចឹងចង់ឲ្យគេកាត់ទោសដែរ?

**ឃួនៈ** ចា៎ស!

**នៃវ៉ាន់:** ចង់ឲ្យគេកាត់ទោសម៉េចទៅ?

**ឃួនៈ** គេកាត់ម៉េច កាត់តាមច្បាប់គេទៅៗ

**នៃវ៉ាន់:** កាត់តាមច្បាប់, អញ្ចឹងមីងអត់ចង់ថា ឲ្យកាត់ទោសប្រហារជីវិតប្រហារអីអត់ចង់ទេ?

**ឃួនៈ** អត់ទេ តាមតែច្បាប់គេទៅ ច្បាប់គេកាត់ទោសម៉េចតាមគេទៅៗ

**នៃវ៉ាន់:** មីងយល់ថាការកាត់ទោសហ្នឹងវាមានប្រយោជន៍អីសម្រាប់មីង សម្រាប់បងប្អូន សម្រាប់អ្នកស្រុកអ្នកភូមិទូទាំងប្រទេសហ្នឹង?

**ឃួនៈ** សម្រាប់អ្នកស្រុកអ្នកភូមិទាំងទូទាំងប្រទេសៗ

**នៃវ៉ាន់:** មីងយល់ថាវាមានប្រយោជន៍អីទៅ ដែលកាត់ទោសពួកអស់ហ្នឹង?

**ឃួនៈ** អត់ដឹងថាមានប្រយោជន៍អី ដូចថាគេកាត់ទោសកាត់ទៅមនុស្សអាក្រក់នោះៗ

**នៃវ៉ាន់:** ម៉េចបានចង់ឲ្យគេកាត់ទោស?

**ឃួនៈ** ចុះបើនឹកឃើញពីជំនាន់ហ្នុងនោះ ជំនាន់បីឆ្នាំហ្នឹងនោះៗ

**នៃវ៉ាន់:** ចុះមីងយល់ម៉េចដែរចំពោះថាពាក្យយុត្តិធម៌?

**ឃួនៈ** យុត្តិធម៌ពាក្យល្អៗ

**នៃវ៉ាន់:** ល្អម៉េចទៅ?

**ឃួនៈ** អ្នកធ្វើល្អ ល្អម៉េចទៅ ធ្វើល្អៗ

**ណៃវ៉ាន់:** ខ្ញុំដូចអត់មានអីចង់បញ្ជាក់បន្ថែមមីងទេ

មីងមានអ៊ីដែលចង់និយាយប្រាប់ពួកខ្ញុំពីរឿងប្រវត្តិ

សាស្ត្រខ្មែរក្រហមដែលខ្ញុំអត់បានសួរនាំមីង ឬក៏យាយដែរអត់?

**ឃួន:** និយាយអីបើគាត់សួរមិញហើយ ។

**ណៃវ៉ាន់:** មានអីចង់បញ្ជាក់បន្ថែមដូចថាមីងចងចាំហើយខ្ញុំអត់ទាន់បានសួរ ហើយមីងគិតថាអាណឹង

សំខាន់ហើយចង់ប្រាប់ខ្ញុំអី?

**ឃួន:** អត់ទេ ប៉ុណ្ណឹងបាន ។

**ណៃវ៉ាន់:** បាទ! អញ្ចឹងខ្ញុំអរគុណមីង អរគុណយាយដែលបានផ្ដល់ពត៏មានទាក់ទងនឹងជិន គាក់ ហៅ

មីនហ្នឹង ហើយនិងប្រវត្តិសាស្ត្ររបស់គាត់ ។ អរគុណយាយ អរគុណមីងបាទ!

**ត្មុំ:** ចា៎ស!